**គណៈកម្មាធិការស្ត្រីកម្ពុជា**

**Cambodian Committee of Women**
**(CAMBOW)**

ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧

# សេចក្តីប្រកាសព័ត៌មាន

## សកម្មភាពយុទ្ធនាការ ១៦ថ្ងៃ ប្រឆាំងអំពើហិង្សាលើយេនឌ័រ

## ថ្ងៃទី ២៥ ខែវិច្ឆិកា ដល់ ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០០៧

---

*ស៊ីថា* អាយុ១៨ឆ្នាំ ត្រូវបានមនុស្សប្រុសម្នាក់ចាប់រំលោភពេលដែលនាងទើបតែមានអាយុ១៥ឆ្នាំ ហើយត្រូវឪពុកម្តាយ និង អាជ្ញាធរមូលដ្ឋានបង្ខំឱ្យរៀបការជាមួយមនុស្សដែលបានចាប់រំលោភរូបនាងទៅវិញ ។*

*សុផាន់ណា* អាយុ៣៥ឆ្នាំ ត្រូវប្តីវាយធ្វើបាបអស់រយៈពេលជាង៥ឆ្នាំកន្លងមក ។ ប្តីរបស់នាង ក៏ប៉ុនប៉ងវាយសំលាប់នាងចោលផង ។*

*រតនា* អាយុ១៩ឆ្នាំ ត្រូវបានមនុស្សប្រុសវ័យស្ទាវ៣នាក់ចាប់រំលោភ ។ ទោះបីជាមានការដាក់ពាក្យបណ្តឹងទៅដល់ប៉ូលីសក៏ដោយ ក៏គ្មានជនណាម្នាក់ទាំងនោះដែលចាប់រំលោភនាង ត្រូវបានគេចាប់ខ្លួននៅឡើយទេ ។*

*សុភា* អាយុ១៩ឆ្នាំ ត្រូវបងប្អូនជួញដូរនឹងបង្ខំឱ្យធ្វើជាស្រីពេស្យា ។ នាងបានប្តឹងចំពោះករណីនេះទៅកាន់តុលាការជាច្រើនលើកច្រើនសារ ប៉ុន្តែ មកដល់ពេលបច្ចុប្បន្ននេះជនល្មើស ដែលជាបងប្អូនរបស់នាងទាំងនោះនៅមិនទាន់ត្រូវបានសមត្ថកិច្ចចាប់ខ្លួននៅឡើយដែរ ។*

*ស៊ីថា, សុផាន់ណា, រតនា និងសុភា** គឺជាក្រុមស្ត្រីរងគ្រោះក្នុងចំណោមស្ត្រីរាប់ពាន់នាក់ ដែលកំពុងស្វែងរកជំនួយពីអង្គការសមាជិកគណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW) ចំពោះអំពើហិង្សាលើស្ត្រី ។ ដំណើររឿងរបស់ពួកគេមានសរសេរនៅក្នុងរបាយការណ៏របស់ CAMBOW ដែលមានចំណងជើងថាៈ *អំពើហិង្សាលើស្ត្រីៈ តើច្បាប់កម្ពុជារើសអើងស្ត្រីរបៀបណា* ដែលនឹងត្រូវចេញផ្សាយនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយរបាយការណ៏នេះនឹងបង្ហាញពីយុទ្ធនាការសកម្មភាព ១៦ថ្ងៃ ប្រឆាំងអំពើហិង្សាលើយេនឌ័រ ឆ្នាំ២០០៧ ផងដែរ ។ របាយការណ៏នេះមានគោលបំណងបង្ហាញពីចំណុចសំខាន់ៗស្តីពីច្បាប់កម្ពុជា ដែលទាក់ទងនឹងអំពើហិង្សាលើស្ត្រីដូចជាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការជួញដូរស្ត្រី និងការរៀបអាពាហ៏ពិពាហ៏ ដែលពេលបច្ចុប្បន្ននេះមានចរិតផ្ទុយពីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រី CEDAW ។ របាយការណ៏នេះ មានគោលបំណងលាតត្រដាងនូវរឿងពិត ដែលស្ត្រីខ្មែរជួបប្រទះនូវការរើសអើងក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។

យុទ្ធនាការ ១៦ថ្ងៃ ២០០៧ នឹងផ្តោតលើបញ្ហាទូទៅនៃការរើសអើងលើស្ត្រីខ្មែរ ដែលទាក់ទងនឹងអំពើហិង្សាលើស្ត្រី។

លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធាន CAMBOW បានមានប្រសាសន៍ថា "ស្ត្រីខ្មែររាប់ពាន់នាក់ទទួលរងអំពើហិង្សាជារៀងរាល់ថ្ងៃ។ បន្ទាប់ពីបានសិក្សាស្រាវជ្រាវ យ៉ាងល្អិតល្អន់លើច្បាប់នានាដែលត្រូវការពារស្ត្រី CAMBOWបានរកឃើញថាខ្លឹមសារមាត្រាខ្លះនៃច្បាប់ទាំងនោះមានលក្ខណៈរើសអើងចំពោះស្ត្រីដោយផ្ទាល់ និង ដោយប្រយោលដែលជាហេតុធ្វើឱ្យមានការរំលោភបំពានបន្ថែមទៀត" ។

លោកស្រីបានបន្តទៀតថា "ឥឡូវជាពេលវេលាដែលរដ្ឋាភិបាលត្រូវធ្វើកំណែទំរង់លើច្បាប់ទាំងនោះ ដើម្បីជួយការពារជនរងគ្រោះពីអំពើហិង្សា។ ប្រសិនបើច្បាប់របស់យើងបំពានផ្ទុយទៅនឹង CEDAW ដែលជាច្បាប់សិទ្ធិស្ត្រីអន្តរជាតិ ហេតុនេះ យើងត្រូវតែធ្វើវិសោធនកម្មមាត្រាច្បាប់ទាំងនេះ ដើម្បីឱ្យកាតព្វកិច្ចរបស់យើងអនុលោមតាម CEDAW ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិនេះនៅឆ្នាំ ១៩៩២" ។

ផ្នែកមួយនៃសកម្មភាពក្នុងយុទ្ធនាការ ១៦ ថ្ងៃនេះ CAMBOW នឹងផ្សព្វផ្សាយស្ព័តតាមប៉ុស្តិ៍វិទ្យុ និងទូរទស្សន៍ដែលរៀបរាប់បង្ហាញពីរឿងពិតនៃការប្រើអំពើហិង្សា និងការរើសអើង ដែលស្ត្រីខ្មែរបានជួបប្រទះកន្លងមក។ CAMBOW ក៏នឹងបោះពុម្ពជាសៀវភៅ និងជាឌីសស្តាប់ (Audio)[1] ដែលមានចំណងជើងថាៈ *អំពើហិង្សាលើស្ត្រីៈ តើច្បាប់កម្ពុជារើសអើងស្ត្រីរបៀបណា* ហើយចែកចាយរបាយការណ៍នេះជាសាធារណៈផងដែរ។

យុទ្ធនាការ ១៦ថ្ងៃ ត្រូវប្រារព្ធឡើងជារៀងរាល់ឆ្នាំ នៅតាមបណ្តាប្រទេសនានាជាច្រើនលើសកលលោកនៅរវាងចន្លោះថ្ងៃទី២៥ ខែវិច្ឆិកា ដែលជាទិវាអន្តរជាតិប្រឆាំងនឹងអំពើហិង្សាលើស្ត្រី និង ថ្ងៃទី១០ ខែធ្នូ ដែលជាទិវាសិទ្ធិមនុស្សអន្តរជាតិ។ យុទ្ធនាការ ១៦ថ្ងៃ ក៏នឹងលើកឡើងនូវព្រឹត្តការណ៍សំខាន់ៗផ្សេងទៀតដូចជា ទិវាអេដស៍ពិភពលោកនៅថ្ងៃទី១ ខែធ្នូ និង ថ្ងៃទី៦ ខែធ្នូ ដែលជាខួបរំលឹកទិវានៃការសម្លាប់រង្គាលលើស្ត្រី១៤ នាក់នៅក្នុងសាលាមួយនៃទីក្រុងម៉ុងត្រេអាល់ (Montreal, Canada) កាលពីឆ្នាំ ១៩៨៩ ។

គណៈកម្មាធិការស្ត្រីកម្ពុជា គឺជាក្រុមសម្ព័ន្ធភាពរវាងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ចំនួន៣៤ ដែលធ្វើសកម្មភាពការងារផ្តោតជាសំខាន់លើការលើកស្ទួយបុព្វហេតុស្ត្រី។ តាមមរយៈសកម្មភាពរបស់ខ្លួន CAMBOW ប្រឹងប្រែងលើកកំពស់ការយល់ដឹងនឹងធ្វើការផ្លាស់ប្តូរផ្នត់គំនិតសង្គមដែលពាក់ព័ន្ធទៅនិងទម្លើប្រើ

[1] ដើម្បីអានអត្ថបទ ឬស្តាប់របាយការណ៍អេឡិចត្រូនិច សូមស្វែងរកក្នុងគេហទំព័រ www.licadho.org ចាប់ពីថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០០៧ តទៅ។

# គណៈកម្មាធិការស្ត្រីកម្ពុជា
# Cambodian Committee of Women (CAMBOW)

អំពើហិង្សាលើស្ត្រី ដោយផ្តោតលើការរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ និងការជួញដូរស្ត្រីដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ។

** ឈ្មោះខាងលើទាំងអស់ត្រូវបានប្តូរ ដើម្បីរក្សាការសម្ងាត់ និង ការគោរពអត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ ។*

**<u>ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ</u>**

- លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធាន គណៈកម្មាធិការស្ត្រីកម្ពុជា CAMBOW តាមរយៈទូរស័ព្ទលេខ ០១២ ៨០២ ៥០៦ ឬ អ៊ីម៉ែលអាសយដ្ឋានៈ (contact@licadho.org)